# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ថ្លែងក្នុង
## ពិធីសម្ពោធជាផ្លូវការ នូវស្ថានតំណាងថ្មី នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំកម្ពុជា

**រាជធានីភ្នំពេញ, ថ្ងៃពុធ ៦ កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨**
**ត្រូវនឹងថ្ងៃទី ១២ ខែ មិថុនា គ.ស. ២០២៤, វេលាម៉ោង ៩ ព្រឹក, អគារវឌ្ឍនៈ**

*****+*****

- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកានៃរាជរដ្ឋាភិបាល;
- ឯកឧត្តម Masatsugu Asakawa, ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB);
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, សមាជិក-សមាជិកានៃអង្គពិធីទាំងមូល, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, មកចូលរួមជាមួយ ឯកឧត្តម Masatsugu Asakawa, ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី (ADB), ព្រមទាំង ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ក្នុង **«ពិធីសម្ពោធស្ថានតំណាងថ្មី នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំព្រះរាជាណាចក្រកម្ពុជា»** ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីដ៏វិសេស នាថ្ងៃនេះ ។

ខ្ញុំសូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅ ចំពោះថ្នាក់ដឹកនាំ និង បុគ្គលិកគ្រប់ជាន់ថ្នាក់ នៃស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំកម្ពុជា,

ដែលទើបទទួលបានការិយាល័យថ្មីសម្រាប់បំពេញការងារ, ដ៏ស្រស់ស្អាត និង ទំនើប, នៅក្នុងអគារវឌ្ឍនៈកាពីតាល់ នេះ ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះដែរ, តាមរយៈ ឯកឧត្តម Masatsugu Asakawa, ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានគាំទ្រ និង កំពុងបន្តស្ថិតនៅជាប់ជាមួយរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា ស្ទើរតែគ្រប់ដំណាក់កាលនៃការវិវត្ត និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង នយោបាយកម្ពុជា, ក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងទៅ ។ ខ្ញុំក៏សូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់ នៃស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំកម្ពុជា, ក្នុងគ្រប់សម័យកាល, ដែលបានខិតខំបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន អស់ពីកម្លាំង-កាយចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការចូលរួមអភិវឌ្ឍន៍កម្ពុជា, តាំងពីដើមរៀងមក, រហូតសម្រេចបានសមិទ្ធផលជាក់ស្តែងជាច្រើន គួរឲ្យកត់-សម្គាល់ ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមកោតសរសើរ និង វាយតម្លៃខ្ពស់ផងដែរ ចំពោះថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានចូលរួមសហការជិតស្និទ្ធ ក្នុងការជំរុញកិច្ចសហប្រតិបត្តិការល្អ រវាងកម្ពុជា និង ADB ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ក្នុងរយៈពេល ២៦ ឆ្នាំចុងក្រោយ, បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធានព្រឹទ្ធសភា**, កម្ពុជាធានាបាននូវអធិបតេយ្យជាតិ, សណ្តាប់ធ្នាប់សង្គម, សន្តិសុខ, សុវត្ថិភាព, និង ស្ថិរភាពនយោបាយ, ព្រមទាំងរក្សាបានយ៉ាងគត់មត់ នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។ មិនតែប៉ុណ្ណោះ, កម្ពុជាបានផ្លាស់ប្តូរមុខមាត់ថ្មីឡើងវិញ, បានកសាងនូវមូលដ្ឋានគ្រឹះរឹងមាំនៃសេដ្ឋកិច្ចជាតិ សម្រាប់ការអភិវឌ្ឍ, និង បានលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនទូទាំងប្រទេស តាមរយៈ៖ ១).**ការពង្រីក និង ការបង្កើនជាបន្តបន្ទាប់** នូវពាណិជ្ជកម្មអន្តរជាតិ ឈរលើគោលការណ៍ពហុភាគីនិយម, រួមទាំងការ-ធ្វើពិពិធកម្មទីផ្សារ និង ទំនិញ, ព្រមទាំងការពង្រឹង និង ការពង្រីកការធ្វើសមាហរណកម្មសេដ្ឋកិច្ច និង ការជំរុញបន្ថែម នូវការតភ្ជាប់ក្នុងតំបន់; ២).**ការជំរុញ និង ការទាក់ទាញ**

**បន្ថែម នូវការវិនិយោគផ្ទាល់ពីបរទេស** តាមរយៈការកែលម្អនូវបរិយាកាសធុរកិច្ច និង ការ-វិនិយោគ; ៣).**ការពង្រឹង និង ការស្ដារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** ដូចជា ផ្លូវថ្នល់, ស្ពាន, ប្រឡាយទឹក និង បណ្ដាញអគ្គិសនី ។ល។ ដើម្បីលើកកម្ពស់ការតភ្ជាប់ និង ភាពប្រកួតប្រជែង; ៤).**ការបន្តអភិវឌ្ឍមូលធនមនុស្ស** ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និង បង្កើនផលិតភាព; និង ៥).**ការកែទម្រង់ស្ថាប័ន និង ការពង្រឹងអភិបាលកិច្ច** ជាប់ជាប្រចាំ ដើម្បីធានានូវប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈគ្រប់ប្រភេទ ។

លើមូលដ្ឋាននេះ, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, និង ឈ្លាសវៃ របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ដោយឈរលើអភិក្រម «**រក្សាសមិទ្ធផលចាស់, បង្កើតសមិទ្ធផលថ្មី**» និង «**គិតគូរជាសកល, ប៉ុន្តែអនុវត្តតាមបរិការណ៍ក្នុងប្រទេស**», រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា បាន និង កំពុងបន្តខិតខំដោះស្រាយបញ្ហាប្រឈមនានា, និង ជាពិសេស, ចាប់ឱ្យជាប់នូវកាលា-នុវត្តភាពដែលផុសឡើង, ក្នុងបរិការណ៍នៃការផ្លាស់ប្ដូរយ៉ាងរហ័សនៃស្ថានភាពសង្គម-សេដ្ឋកិច្ចតំបន់ និង សកលលោក ។ ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព** និង **ចីរភាព** ដោយកំណត់យកនូវ **អាទិភាពគន្លឹះចំនួន ៥** គឺ៖ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និង បច្ចេកវិទ្យា**, ជាពិសេស **បច្ចេកវិទ្យាឌីជីថល** ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤.០ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជា ដើម្បីលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ ក្នុងការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលខ្ពស់ ។

លើមូលដ្ឋាននៃកិច្ចប្រឹងប្រែងយ៉ាងសកម្ម និង ប្រកបដោយភាពបុរេសកម្មទាំងអស់នេះ, សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ ២០២៣ កន្លងទៅ ត្រូវបានវាយតម្លៃថា សម្រេចបានកំណើនក្នុងអត្រាប្រមាណ ៥%, ហើយសម្រាប់ឆ្នាំ ២០២៤ នេះ, ត្រូវបានព្យាករណ៍ថា នឹងបន្តស្ទុះឡើង ក្នុងអត្រាប្រមាណ ៦%, ដោយសារការត្រលប់ទៅរកភាពល្អឡើងវិញនៃសេដ្ឋកិច្ចសកល, ជាពិសេស ប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ស្របពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក នៅបន្តរក្សាស្ថិរភាព និង និន្នាការល្អ, គួបផ្សំជាមួយនឹងការខិតខំយ៉ាងប្ដូរផ្ដាច់របស់រាជរដ្ឋាភិបាល, ក្នុងការជំរុញការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រនានារបស់ខ្លួន, ជាពិសេស ការស្ដារវិស័យចន្ទល់កំណើនដែលមានស្រាប់,

ក៏ដូចជា ការលើកកម្ពស់វិស័យសក្ដានុពលថ្មីមួយចំនួនទៀត, រួមទាំងការវិនិយោគលើសហគ្រាសធុនមីក្រូ, តូច, និង មធ្យម, និង ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ផងដែរ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ, ខ្ញុំសូមគូសរំលេចដោយសង្ខេបអំពីប្រវត្តិដ៏យូរលង់ នៃកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និង ADB ។ កម្ពុជាបានចូលជាសមាជិករបស់ ADB ក្នុងឆ្នាំ ១៩៦៦ ក្នុងខណៈដែល ADB ទើបត្រូវបានបង្កើតឡើងនៅហ្វីលីពីន ។ ក្នុងឆ្នាំ ១៩៧០, ADB បានផ្ដល់ឥណទានដំបូងដល់កម្ពុជា ក្នុងទំហំទឹកប្រាក់សរុបចំនួន **១,៦៧ លានដុល្លារអាមេរិក** សម្រាប់គម្រោង «Phnom Penh High Voltage Transmission» ។ ជាអកុសល, ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩០, កិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និង ADB ត្រូវបានផ្អាក ដោយសារសង្គ្រាម និង ស្ថានភាពដ៏លំបាកស្មុគស្មាញនៅកម្ពុជានាពេលនោះ, ជាពិសេស ដោយសាររបបប្រល័យពូជសាសន៍ ប៉ុល ពត, ដែលបានធ្វើឲ្យប្រជាជនកម្ពុជា រាប់លាននាក់ ស្លាប់ និង រងទុក្ខវេទនា ព្រមទាំង បានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនានា ស្ទើរតែទាំងស្រុង រួមមាន៖ ផ្លូវថ្នល់, ស្ពាន, ប្រព័ន្ធធារាសាស្ត្រ, សាលារៀន, មន្ទីរពេទ្យ, និង ផ្ទះសម្បែងរបស់ប្រជាជន ។ល។

នៅឆ្នាំ ១៩៩១ និង ១៩៩២, ទោះបីជាមានក្ដីព្រួយបារម្ភអំពីបញ្ហាអស្ថិរភាព និង អសន្តិសុខខ្ពស់ ដោយសារសង្គ្រាមស៊ីវិល, ចោរកម្ម និង ភាពច្របូកច្របល់នៅកម្ពុជាយ៉ាងណាក្ដី, ក៏ ADB នៅតែស្ម័គ្រចិត្តបញ្ជូនក្រុមបេសកកម្មជាច្រើនក្រុម មកកាន់កម្ពុជា ដើម្បីវាយតម្លៃ អំពីតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កំណត់វិស័យអាទិភាពនានា ព្រមទាំងដើម្បីកំណត់ក្របខណ្ឌគតិយុត្ត និង ក្របខណ្ឌសហប្រតិបត្តិការ ក្នុងការផ្ដល់ហិរញ្ញប្បទាន ដើម្បីគាំទ្រការស្ដារ និង ការអភិវឌ្ឍនៅកម្ពុជាឡើងវិញ ។ នៅខែ វិច្ឆិកា ឆ្នាំ ១៩៩២, ពោលគឺ ត្រឹមតែមួយឆ្នាំ បន្ទាប់ពីការចុះហត្ថលេខា លើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស, ADB បានផ្ដល់ឥណទានដល់កម្ពុជា ក្នុងទំហំទឹកប្រាក់ សរុបចំនួន **៦៧,៧ លានដុល្លារអាមេរិក**, សម្រាប់ឆ្នាំ ១៩៩២ ដល់ឆ្នាំ ១៩៩៦, ដើម្បីស្ដារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ក្នុងវិស័យសំខាន់ ចំនួន ៤ រួមមាន៖ វិស័យដឹកជញ្ជូន, វិស័យថាមពល, វិស័យកសិកម្ម, និង វិស័យអប់រំ ។ ទន្ទឹមនេះ, ADB ក៏បានផ្ដល់ជំនួយបច្ចេកទេសចំនួន **៤,២ លានដុល្លារអាមេរិក** ដើម្បីគាំទ្រដល់ភ្នាក់ងារអនុវត្តគម្រោង ដែលទទួលបន្ទុកលើការស្ដារឡើងវិញនៃហេដ្ឋារចនាសម្ព័ន្ធអាទិភាពនានា ។

ជារួម, ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ៩០, ADB បានគាំទ្រកម្ពុជា ក្នុងការស្តារឡើងវិញនូវផ្លូវជាតិសំខាន់ៗ, សរុបចំនួន **៥៦០** គីឡូម៉ែត្រ និង ស្ពានចំនួន **២៣,** ព្រមទាំងក្នុងការ-ជួសជុលបណ្តាញផ្លូវដែក នៅទីតាំងសំខាន់មួយចំនួន ផងដែរ ។ នៅក្រុងព្រះសីហនុ, ADB បានគាំទ្រដល់ការជំរុញពាណិជ្ជកម្ម តាមរយៈការស្តារឡើងវិញ នូវកំពង់ផែទឹកជ្រៅរបស់កម្ពុជា ។ ចំណែកនៅភ្នំពេញវិញ, ហិរញ្ញប្បទានរបស់ ADB បានគាំទ្រដល់ការដំឡើងម៉ាស៊ីនភ្លើងថ្មី និង ជួសជុលម៉ាស៊ីនភ្លើងដែលមានស្រាប់ ដើម្បីស្តារឡើងវិញនូវបណ្តាញចែកចាយអគ្គិសនី ។ លើសពីនេះ, ប្រព័ន្ធធារាសាស្ត្រ និង ប្រព័ន្ធគ្រប់គ្រងទឹកជំនន់ ចំនួន **៤** ត្រូវបានជួសជុលឡើងវិញ ដែលមានសមត្ថភាពស្រោចស្រពលើផ្ទៃដីស្រែ ចំនួន **១** ម៉ឺនហិចតា, ដោយក្នុងនោះ, ADB ក៏បានជួយដល់ការផ្គត់ផ្គង់ឧបករណ៍សំណង់, គ្រឿងបន្លាស់, និង ប្រព័ន្ធកុំព្យូទ័រ ដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការអនុវត្តកិច្ចការនេះ ផងដែរ ។ ចំពោះវិស័យអប់រំ, ហិរញ្ញប្បទានរបស់ ADB បានគាំទ្រដល់ការជួសជុល និង ការបំពាក់គ្រឿងបរិក្ខារ សម្រាប់អនុវិទ្យាល័យ ចំនួន **៦៧**, វិទ្យាស្ថានបច្ចេកទេស ចំនួន **៣** និង មហាវិទ្យាល័យគរុកោសល្យ ចំនួន **២** ។

គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៣, ADB បានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់កម្ពុជា សម្រាប់ហិរញ្ញប្បទានគម្រោងអភិវឌ្ឍន៍ ចំនួន **២០៧** ដែលមានទឹកប្រាក់សរុបចំនួនប្រមាណ **៤,៨ ប៊ីលានដុល្លារអាម៉េរិក** រួមមាន៖ (១). **ឥណទានសម្បទាន** ចំនួនប្រមាណ **៤,២ ប៊ីលានដុល្លារអាម៉េរិក** សម្រាប់ហិរញ្ញប្បទានគម្រោង ចំនួន **១៣៧**, ក្នុងនោះ, គម្រោង ចំនួន **៨៨** បានបញ្ចប់ និង គម្រោង ចំនួន **៤៩** កំពុងដំណើរការ; និង **(២). ហិរញ្ញប្បទានឥតសំណង** ចំនួនប្រមាណ **៥៦៨ លានដុល្លារអាម៉េរិក** សម្រាប់ហិរញ្ញប្បទានគម្រោង ចំនួន **៧០,** ក្នុងនោះ, គម្រោង ចំនួន **៤៤** បានបញ្ចប់ និង គម្រោង ចំនួន **២៦** កំពុងដំណើរការ ។ ហិរញ្ញប្បទានសហប្រតិបត្តិការទាំងអស់នេះ ត្រូវបានប្រើប្រាស់សម្រាប់ការវិនិយោគលើវិស័យអាទិភាពមួយចំនួន ដូចជា៖ វិស័យកសិកម្ម និង ធនធានធម្មជាតិ, វិស័យផ្គត់ផ្គង់ទឹកស្អាត និង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង, វិស័យគមនាគមន៍ និង បច្ចេកវិទ្យា-ព័ត៌មាន, វិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម, វិស័យហិរញ្ញវត្ថុ, វិស័យគ្រប់គ្រងសាធារណៈ, វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, វិស័យសុខាភិបាល, វិស័យថាមពល ។ល។

បន្ថែមពីលើការចូលរួមក្នុងកិច្ចដំណើរការអភិវឌ្ឍន៍កម្ពុជា ក្នុងវិស័យអាទិភាពនានា ដូចខ្ញុំបានគូសបញ្ជាក់ខាងលើនេះ, តាមរយៈកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាលកម្ពុជា, ADB ក៏បានចូលរួមចំណែក ក្នុងការឆ្លើយតបយ៉ាងរហ័ស ចំពោះគ្រោះមហន្តរាយ និង បញ្ហាប្រឈមនានា ដែលបានកើនឡើងនៅកម្ពុជា រួមមាន៖ ១).ការឆ្លើយតបយ៉ាងរហ័ស ទៅនឹងបញ្ហាគ្រោះទឹកជំនន់ធ្ងន់ធ្ងរនៅកម្ពុជា ក្នុងឆ្នាំ ២០០០ និង ឆ្នាំ ២០១១ តាមរយៈការផ្តល់នូវហិរញ្ញប្បទានសហប្រតិបត្តិការ សរុបប្រមាណ **១១៥ លានដុល្លារអាម៉េរិក** សម្រាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ដែលបានខូចខាតដោយទឹកជំនន់; ២).ការគាំទ្រកម្ពុជា ក្នុងការទប់ទល់នឹងការកើនឡើងនៃតម្លៃស្បៀង និង បញ្ហាអតិផរណា ក្នុងឆ្នាំ ២០០៨ តាមរយៈការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ សរុបប្រមាណ **៣៥ លានដុល្លារអាម៉េរិក** សម្រាប់គម្រោងជំនួយស្បៀងអាហារបន្ទាន់; និង ៣).ការគាំទ្រកម្ពុជា ក្នុងការឆ្លើយតបយ៉ាងឆាប់ និង ទាន់ពេល ទៅនឹងវិបត្តិនៃជំងឺកូវីដ-១៩ តាមរយៈការផ្តល់ហិរញ្ញប្បទាន សរុបចំនួន **២៥០ លានដុល្លារអាម៉េរិក** ក្រោមក្របខណ្ឌកម្មវិធី «ADB's COVID-19 Active Response and Expenditure Support (CARES) Program» ដើម្បីជួយពង្រឹងប្រព័ន្ធសុខាភិបាល និង ពង្រឹងប្រព័ន្ធគាំពារសង្គម, ជាពិសេស សម្រាប់គ្រួសារក្រីក្រ និង ជនងាយរងគ្រោះ, ព្រមទាំងបានផ្តល់ឥណទានសម្បទាន សរុបចំនួន **៩៥ លានដុល្លារអាម៉េរិក** ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់ប្រជាជនកម្ពុជា, ពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៣ ។

ឆ្លៀតក្នុងឱកាសដ៏កម្រនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ADB ដែលទើបបានអនុម័ត នូវ **យុទ្ធសាស្ត្រនៃភាពជាដៃគូសម្រាប់អភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០២៤-២០២៨** កាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២៤ កន្លងទៅនេះ, ដែលក្នុងនោះ, ADB គ្រោងនឹងផ្តល់ហិរញ្ញប្បទានផ្ទាល់ ក្នុងទំហំទឹកប្រាក់ សរុបប្រមាណ **១ ២៦៣ លានដុល្លារអាម៉េរិក,** ដែលមាន **ឥណទានសម្បទាន** សរុបប្រមាណ **១ ២៥១ លានដុល្លារអាម៉េរិក** និង **ហិរញ្ញប្បទានឥតសំណង** សរុបប្រមាណ **១១ លានដុល្លារអាម៉េរិក**, ព្រមទាំងបានចូលរួមកៀរគរសហហិរញ្ញប្បទាន ពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត សរុបប្រមាណ **២៨៣ លានដុល្លារអាម៉េរិក** សម្រាប់គម្រោង និង កម្មវិធី ចំនួន **២២** ។ **យុទ្ធសាស្ត្រនៃភាពជាដៃគូ** នេះ នឹងជួយជំរុញល្បឿននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅសម្រេចបាននូវ **បង្គោលចរ ឆ្នាំ ២០៣០** ក្នុងការប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និង សម្រេចបាននូវ **ចក្ខុវិស័យ ឆ្នាំ ២០៥០** ក្នុងការប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលខ្ពស់ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ, ជាថ្មីម្ដងទៀត, ចំពោះ ឯកឧត្តម **Masatsugu Asakawa,** ប្រធាន ADB, ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់នៃ ADB, ដែលបាន និង កំពុងផ្ដល់កិច្ចសហប្រតិបត្តិការស្អិតល្មួត និង ភាពជា-ដៃគូជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ADB នឹងបន្តសហការកាន់តែជិតស្និទ្ធ និង ផ្ដល់ការគាំទ្រកាន់ខ្លាំងក្លាបន្ថែមទៀត ដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្តជំរុញការអភិវឌ្ឍលើវិស័យអាទិភាពទាំងឡាយ សំដៅចូលរួមលើកកម្ពស់ជីវភាព និង កាត់បន្ថយភាពក្រីក្រ របស់ប្រជាជនកម្ពុជា ។

ជាទីបញ្ចប់, ជាមួយនឹងការប្រកាសសម្ពោធជាផ្លូវការ នូវស្ថានតំណាងថ្មីនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំព្រះរាជាណាចក្រកម្ពុជា, ក្នុងនាម **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមជូនពរ **ឯកឧត្តម ប្រធាន ADB**, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ដែលមានវត្តមាននៅទីនេះ, បានប្រកបដោយសុខភាពល្អបរិបូរណ៍, កម្លាំងមាំមួន, មានសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ៕

*សូមអរគុណ !*